**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..០០៥.......សហវ.-ពសហ

# សេចក្តីជូនដំណឹង

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** មានកិត្តិយសជម្រាបជូនដំណឹងដល់សាធារណៈជនទាំងពីរភេទ ជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតម្រូវការប្រឡងជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា ចំនួន ១២ នាក់ ដើម្បីមកបម្រើផ្នែកវិភាគធុរកិច្ច (Business Analyst) នៅនាយកដ្ឋានព័ត៌មានវិទ្យា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ នៅពេលបញ្ចប់កិច្ច-សន្យារយៈពេល ០២ ឆ្នាំ មន្ត្រីទាំងនេះអាចនឹងមានឱកាសក្លាយជាមន្ត្រីរាជការពេញសិទ្ធរបស់ក្រសួង ក្នុងករណីដែលក្រសួងមានតម្រូវការ និងផ្អែកតាមគុណសម្បត្តិនៃការខិតខំបំពេញភារកិច្ចរបស់មន្ត្រីនីមួយៗ។

សាធារណៈជនទាំងពីរភេទ ដែលមានបំណងចូលរួមការប្រឡងជ្រើសរើសនេះ ត្រូវមានលក្ខណៈសម្បត្តិដូចតទៅ :

១. មានសញ្ញាប័ត្របរិញ្ញាប័ត្រផ្នែកគណនេយ្យ ហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ( មុខវិជ្ជាដែលត្រូវប្រឡង) ។

២. មានចំណេះដឹងផ្នែកភាសាអង់គ្លេស ( មុខវិជ្ជាដែលត្រូវប្រឡង) ។

៣. មានចំណេះដឹងផ្នែកព័ត៌មានវិទ្យា។

៤. មានអាយុមិនលើសពី ៣៥ ឆ្នាំ។

សេចក្តីដូចបានជម្រាបជូនខាងលើ ប្រសិនបើសាធារណៈជន មានបំណងចូលរួមការប្រឡងជ្រើសរើសនេះ សូមអញ្ជើញមកដាក់ពាក្យ និងបំពេញបែបបទនៅ **វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានអាសយដ្ឋានផ្លូវលេខ ៩០ សង្កាត់ វត្តភ្នំ ខ័ណ្ឌ ដូនពេញ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣០ខែកក្ក ឆ្នាំ ២០១០។ កាលបរិច្ឆេទនៃការប្រឡង និងបញ្ជីរាយនាមបេក្ខជនដែលត្រូវប្រឡង នឹងមានបិទផ្សាយជូននៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០១០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**